JITCO

# とも

## ～ស្វែងយល់បន្ថែមអំពីប្រទេសជប៉ុន～

2025

10

លេខរដូវស្លឹកឈើជ្រុះ

មកដឹងតាមរយៈតុក្កតា

### ពិធីបុណ្យសែនព្រះខែ



នៅរដូវស្លឹកឈើជ្រុះ ផ្ទៃមេឃពេលយប់នឹងបង្ហាញដួងព្រះចន្ទដ៏ស្រស់ស្អាត ដូច្នេះ តាំងពីសម័យដើមមក នៅប្រទេសជប៉ុនគឺមានទំនៀមទម្លាប់ប្រារព្ធ"ពិធីបុណ្យសែនព្រះខែ"។ នៅយប់ដប់ប្រាំកើត (ត្រូវនឹងចន្ទគតិថ្ងៃទី15 ខែសីហា) ព្រះចន្ទគឺមានសម្រស់ស្រស់ស្អាតជាងគេក្នុងមួយឆ្នាំ ហើយសម្រាប់ជាពិធីថ្លែងអំណរគុណនិងអបអរជូនពរដល់ការប្រមូលផលនារដូវស្លឹកឈើជ្រុះ ប្រជាជនជប៉ុននឹងនាំគ្នាតុបតែងលម្អរុក្ខជាតិស៊ុស៊ុគី ហើយបរិភោគនំសែនព្រះខែ ព្រមទាំងគយគន់ដួងចន្ទដ៏ស្រស់ស្អាតដោយក្ដីស្រឡាញ់។ ម្យ៉ាងទៀត នៅប្រទេសជប៉ុន គេតែងនិយាយថាឃើញមានរូបសត្វទន្សាយកំពុងបុកនំដែលបង្ហាញពណ៌ខ្មៅនៅលើផ្ទៃនៃដួងព្រះចន្ទ ដោយនៅតំបន់នីមួយៗនៅលើពិភពលោកគឺមានទេវកថានិងរឿងនិទានជាច្រើនដែលនិយាយទាក់ទងនឹងព្រះចន្ទ។ យប់ដប់ប្រាំកើតសម្រាប់ឆ្នាំ2025 គឺត្រូវនឹងថ្ងៃទី6 ខែតុលា។ សូមអ្នកទាំងអស់គ្នាក៏ចូលរួមរីករាយជាមួយនឹងការគយគន់ដួងព្រះចន្ទដ៏ស្រស់ស្អាតបំផុតក្នុងមួយឆ្នាំផងដែរ។

"Tomo" ត្រូវបានបោះពុម្ពផ្សាយជាភាសាជប៉ុនដែលភ្ជាប់ដោយសម្លេងអាន និង ជាភាសាចំនួន9ទៀត (វៀតណាម ចិន ហ្វីលីពីន ឥណ្ឌូនេស៊ី ថៃ ខ្មែរ មីយ៉ាន់ម៉ា ម៉ុងហ្គោលី និងអង់គ្លេស) ដើម្បីផ្ដល់ព័ត៌មានដែលមានប្រយោជន៍សម្រាប់ការរស់នៅក្នុងប្រទេសជប៉ុននិងផ្ដល់នូវគន្លឹះនានាសម្រាប់ការសិក្សាភាសាជប៉ុន។
（https://www.jitco.or.jp/ja/tomo/）



# យើងនាំគ្នាស្វែងយល់ ! អំពីច្បាប់ចរាចរណ៍សម្រាប់កង់

គិតចាប់ពីខែមេសា ឆ្នាំ2026 តទៅ

ការជិះកង់ដែលល្មើសវិន័យ គឺ

នឹងទទួលការផាកពិន័យ។



កង់ត្រូវបានប្រើប្រាស់ជាញឹកញាប់ ព្រោះជាមធ្យោបាយធ្វើដំណើរដែលផ្តល់ភាពងាយស្រួលជាខ្លាំង។ ដើម្បីបង្ការការកើតឡើងនៃគ្រោះថ្នាក់ចរាចរណ៍នៅពេលជិះកង់ ចូរយើងនាំគ្នាស្វែងយល់ម្តងទៀតអំពីច្បាប់ចរាចរណ៍ដែលត្រឹមត្រូវ។

## របៀបនៃការជិះកង់ ~វិន័យសំខាន់ៗទាំង5~

1. ត្រូវជិះកង់នៅខាងឆ្វេងនៃផ្លូវរថយន្ត
កង់ត្រូវបានចាត់ចូលជាយានជំនិះប្រភេទរថយន្ត ដូច្នេះ ក្រៅពីករណីលើកលែងមួយចំនួន កង់ចាំបាច់ត្រូវបរនៅខាងឆ្វេងនៃផ្លូវរថយន្ត។ ទោះជាកង់អាចបរនៅលើផ្លូវដើរក៏ដោយ នៅទីនោះគឺត្រូវផ្តល់អាទិភាពដល់អ្នកថ្មើរជើង។ សូមអ្នកជិះកង់ដោយយឺតៗនៅខាងក្បែរផ្លូវរថយន្ត។
2. នៅផ្លូវប្រសព្វ សូមអ្នកគោរពភ្លើងសញ្ញាចរាចរណ៍និងឈប់បណ្តោះអាសន្នដើម្បីពិនិត្យសុវត្ថិភាព។
3. នៅពេលយប់ សូមអ្នកបើកភ្លើងកុំខានឱ្យសោះ។
4. អ្នកមិនត្រូវជិះកង់ទាំងពិសាគ្រឿងស្រវឹងនោះទេ។
5. សូមព្យាយាមពាក់មួកសុវត្ថិភាព ដើម្បីកាត់បន្ថយការរងគ្រោះដោយសារឧបទ្ទវហេតុ។




ក្រៅពីនេះ ការជិះកង់បណ្តើរដោយប្រើទូរសព្ទដៃបណ្តើរ និង ការជិះកង់ទាំងកាន់ឆ័ត្រ ក៏ត្រូវបានហាមឃាត់ផងដែរ។






ករណីអ្នកមិនគោរពទៅតាមវិន័យទាំងនេះទេ អ្នកនឹងទទួលការផាកពិន័យ។ គិតចាប់ពីខែមេសា ឆ្នាំ2026 តទៅ គឺនឹងមានការរឹតបន្តឹងនូវការជូនដំណឹងឱ្យបង់ប្រាក់ផាកពិន័យសម្រាប់អ្នកដែលបានល្មើសវិន័យដូចក្នុងករណីរថយន្តនិងម៉ូតូផងដែរ។ ឧទាហរណ៍ ចំពោះ"ការជិះកង់បណ្តើរ"និងប្រើទូរសព្ទដៃបណ្តើរគឺនឹងត្រូវបង់ប្រាក់ចំនួន 12,000 យេន ហើយករណីជិះកង់ដោយមិនបើកភ្លើងនៅពេលយប់គឺនឹងត្រូវបង់ប្រាក់ចំនួន 5,000 យេន ។ល។

សូមអ្នកប្រុងប្រយ័ត្នគោរពច្បាប់ចរាចរណ៍ជានិច្ច ដើម្បីបើកបរប្រកបដោយសុវត្ថិភាព។

出典：「広報けいしちょう」春号（第111号）より抜粋し、JITCOが作成

### ទស្សនានិងសិក្សាអំពីច្បាប់ចរាចរណ៍

នៅទំព័រលក់ទំនិញអនឡាញគឺមានការដាក់លក់នូវសម្ភារសិក្សារបស់JITCO ដែលជាវីដេអូ DVD ចំណងជើងថា "ចងចាំតាមរយៈសំណួរចម្លើយអំពីសុវត្ថិភាពចរាចរណ៍នៅប្រទេសជប៉ុន ~វិន័យនៅក្នុងការដើរនិងការជិះកង់~"។ វីដេអូនេះត្រូវបានថតជាភាសាចំនួន5 គឺ ជប៉ុន ចិន អង់គ្លេស ឥណ្ឌូនេស៊ី និង វៀតណាម។ សូមអ្នកប្រើប្រាស់វីដេអូនេះសម្រាប់ជាប្រយោជន៍។




Q&A で覚える日本の交通安全
～歩行と自転車のルール～

## តើអ្នកបាន "ត្រៀម" ទប់ទល់នឹងគ្រោះមហន្តរាយរួចរាល់ឬនៅ?



គ្រោះមហន្តរាយអាចកើតឡើងពេលណាក៏យើងមិនដឹង ដូច្នេះ ការត្រៀមខ្លួនតាំងពីពេលធម្មតាទៅគឺមានសារៈសំខាន់។ សូមអ្នកប្រមូលវត្ថុដែលនឹងយកតាមខ្លួននៅពេលមានគ្រោះមហន្តរាយដាក់ចូលទៅក្នុងកាបូបស្ពាយជាដើមទុកជាមុន ដើម្បីអាចស្ពាយយកទៅតាមខ្លួនបានភ្លាមៗ។

### យើងនាំគ្នាត្រៀមសម្ភារទប់ទល់នឹងគ្រោះមហន្តរាយ

- ☑ ទឹកសម្រាប់បរិភោគ
- ☑ អាហារ ៖ សម្រាប់អាហារ សូមត្រៀមអាហារដែលអាចបរិភោគបានទោះនៅពេលមិនអាចប្រើភ្លើងក៏ដោយ ដូចជាអាហារកំប៉ុង នំប៉័ងក្រៀម នំប៊ីស្គីត។ល។
- ☑ សម្ភារប្រើប្រាស់ក្នុងជីវភាពរស់នៅ ៖ ពិល ចង្កៀនហ្គាសចល័ត ដុំសាកថ្មចល័ត(Power bank) ។ល។
- ☑ សម្ភាររក្សាអនាម័យ ៖ ខោក្នុង កន្សែង ក្រដាសជូតសើម ច្រាសដុសធ្មេញ ថ្នាំដុសធ្មេញ ម៉ាស់ សម្ភារប្រើប្រាស់ពេលមករដូវ ។ល។
- ☑ សម្ភារសង្គ្រោះបន្ទាន់ ៖ បង់បិទដំបៅ ថ្នាំសម្លាប់មេរោគ។ គួរដាក់ឱសថរក្សាទុកជាប្រចាំជាដើមចូលផងដែរ។



ទន្ទឹមនឹងនោះ សូមពិនិត្យរកទុកជាមុននូវ — "ទីកន្លែងភៀសខ្លួន" និង "ទីលំនៅភៀសខ្លួន" —

"ទីកន្លែងភៀសខ្លួន" គឺសំដៅទៅលើទីកន្លែងដែលយើងត្រូវភៀសខ្លួនទៅ។
គឺជាទីកន្លែងដែលយើងត្រូវភៀសខ្លួនទៅជាបណ្តោះអាសន្ន នៅពេលកើតមានគ្រោះមហន្តរាយធំ។ ទីធ្លាសាលារៀនឬសួនសាធារណៈជាដើមត្រូវបានកំណត់ធ្វើជាទីកន្លែងភៀសខ្លួន។

"ទីលំនៅភៀសខ្លួន" គឺសំដៅទៅលើទីកន្លែងដែលយើងអាចរស់នៅបានក្រោយពេលភៀសខ្លួន។
ករណីការស្នាក់នៅក្នុងផ្ទះអាចមានគ្រោះថ្នាក់ដោយសារគ្រោះរញ្ជួយដីធំឬព្យុះទីហ្វុងជាដើម ឬក៏ ករណីពិបាកបន្តជីវភាពរស់នៅនៅទីកន្លែងដែលកំពុងស្នាក់នៅដោយសារប្រព័ន្ធបណ្តាញហ្គាសឬអគ្គិសនីឬទឹកផ្អាកដំណើរការ យើងអាចស្នាក់នៅទីលំនៅភៀសខ្លួនបានក្នុងរយៈពេលកំណត់មួយ។ នរណាក៏អាចប្រើប្រាស់ទីលំនៅភៀសខ្លួនបានដែរ ប៉ុន្តែ សូមអ្នកគោរពវិន័យដែលបានកំណត់រួចជាស្រេចកុំខានឱ្យសោះ។

អ្នកអាចពិនិត្យរកទីកន្លែងភៀសខ្លួនឬទីលំនៅភៀសខ្លួននៅលើគេហទំព័រនៃអាជ្ញាធរមានសមត្ថកិច្ចឬតាមរយៈផែនទីពេលអាសន្នជាដើមសម្រាប់ទីកន្លែងដែលអ្នកកំពុងរស់នៅ។

政府広報オンライン（https://www.gov-online.go.jp/article/201108/entry-8072.html）より抜粋し JITCO が作成

とも
2025年10月 秋季号
2025年10月1日発行

発　行　公益財団法人 国際人材協力機構（JITCO）
総務部広報室
〒108-0023
東京都港区芝浦2-11-5
五十嵐ビルディング
電　話　03-4306-1166（ダイヤルイン）
JITCO ホームページ　https://www.jitco.or.jp/

jitco.official
@jitco_official